ក្រសួងផែនការ

អគ្គនាយកដ្ឋានផែនការ

នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

# សេចក្តីណែនាំនិយាម
# ស្តីពីការចុះតាមដានត្រួតពិនិត្យ និងការគ្រប់គ្រងមតិជំទាស់
# និងសំណូមពរនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

ខែសីហា ឆ្នាំ២០២៤

# មាតិកា

**អារម្ភកថា**
**ជំពូក១៖ សេចក្តីណែនាំនិយាម ស្តីពីការចុះតាមដានត្រួតពិនិត្យ និងការបណ្តុះបណ្តាលបន្ថែម របស់មន្រ្តីនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ** ........ 1
១.១. គោលបំណងនៃសេចក្តីណែនាំនិយាម ........ 1
១.២.សកម្មភាពតាមដានត្រួតពិនិត្យ និងការបណ្តុះបណ្តាលបន្ថែម ........ 1
១.៣.សកម្មភាពមុនពេលចុះតាមដាន ........ 1
ក. ការរៀបចំសំណាកឃុំ សង្កាត់ ........ 1
ខ. ការរៀបចំផែនការសកម្មភាពចុះតាមដានត្រួតពិនិត្យ ........ 2
១.៤. អំឡុងពេលចុះតាមដានត្រួតពិនិត្យ ........ 2
ក. សកម្មភាពសម្ភាសន៍ឃុំ សង្កាត់ និងបណ្តុះបណ្តាលបន្ថែម ........ 2
ខ. សកម្មភាពសម្ភាសន៍គ្រួសារ ........ 3
គ. សកម្មភាពប្រជុំជាមួយមន្ទីរផែនការរាជធានី ខេត្ត និងបណ្តុះបណ្តាលបន្ថែម ........ 4
១.៥. សកម្មភាពក្រោយពីចុះតាមដានត្រួតពិនិត្យ ........ 4
**ជំពូក២៖ សេចក្តីណែនាំនិយាមស្តីពីការចុះតាមដានត្រួតពិនិត្យ និងការបណ្តុះបណ្តាលបន្ថែម ដល់ឃុំ សង្កាត់របស់មន្ទីរផែនការរាជធានី ខេត្ត** ........ 6
២.១. គោលបំណងនៃសេចក្តីណែនាំនិយាម ........ 6
២.២. សកម្មភាពតាមដានត្រួតពិនិត្យ និងការបណ្តុះបណ្តាលបន្ថែម ........ 6
២.៣.សកម្មភាពមុនពេលចុះតាមដានត្រួតពិនិត្យ ........ 6
ក. ការរៀបចំសំណាកឃុំ សង្កាត់ ........ 6
ខ. ការរៀបចំសំណាកគ្រួសារ ........ 7
គ. ការរៀបចំផែនការសកម្មភាព ........ 7
២.៤. កំឡុងពេលចុះតាមដានត្រួតពិនិត្យ ........ 7
ក. សកម្មភាពសម្ភាសន៍ឃុំ សង្កាត់ និងបណ្តុះបណ្តាលបន្ថែម ........ 7
ខ. សកម្មភាពសម្ភាសន៍គ្រួសារ ........ 8
២.៥. លទ្ធផលក្រោយពេលចុះតាមដានត្រួតពិនិត្យ ........ 9
**ជំពូក៣៖ សេចក្តីណែនាំនិយាម ស្តីពីការគ្រប់គ្រងមតិជំទាស់ និងសំណូមពររបស់មន្ត្រីតាមដានត្រួតពិនិត្យការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃមន្ទីរផែនការថ្នាក់រាជធានី ខេត្ត** ........ 10
៣.១. គោលបំណង ........ 10
៣.២. តួនាទី និងភារកិច្ច ........ 10
៣.៣. ដំណោះស្រាយ ........ 10
៣.៤. របាយការណ៍លទ្ធផល ........ 11

# អារម្ភកថា

ក្រសួងផែនការ គឺជាស្ថាប័នគ្រប់គ្រងដំណើរការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅព្រះរាជាណាចក្រកម្ពុជា។ ទិន្នន័យគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់កំណត់អត្តសញ្ញាណគ្រួសារ ដែលត្រូវទទួលសេវាជំនួយសង្គមពីរាជរដ្ឋាភិបាល។

ក្រសួងផែនការ បានដំណើរការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រចាប់តាំងពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០២០ ដោយអនុវត្តតាមជុំ ហើយធ្វើបច្ចុប្បន្នភាពទិន្នន័យរៀងរាល់៣ឆ្នាំម្តង។ ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩ ក្រសួងផែនការបានផ្លាស់ប្តូរយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រពីការអនុវត្តតាមជុំមកអនុវត្តតាមការស្នើសុំជាប្រចាំ។ ក្រុមការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រឃុំ សង្កាត់ (ហៅថាក្រុមការងារឃុំ សង្កាត់) និងក្រុមប្រឹក្សាឃុំ សង្កាត់ មានតួនាទីទទួលពាក្យស្នើសុំពីប្រជាពលរដ្ឋ ចុះទៅសម្ភាសន៍គ្រួសារ អនុម័តលើលទ្ធផលនៃការសម្ភាសន៍ និងកែសម្រួលព័ត៌មានគ្រួសារ។ល។

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តនីតិវិធី គុណភាពទិន្នន័យ និងពង្រឹងសមត្ថភាពអ្នកអនុវត្ត នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការបានរៀបចំសេចក្តីណែនាំនិយាមជា ៣ជំពូកសម្រាប់៖

១.ការចុះតាមដានត្រួតពិនិត្យ និងការបណ្តុះបណ្តាលបន្ថែមរបស់មន្ត្រីនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

២.សេចក្តីណែនាំនិយាម ស្តីពីការចុះតាមដានត្រួតពិនិត្យ និងការបណ្តុះបណ្តាលបន្ថែមដល់ឃុំ សង្កាត់របស់មន្ទីរផែនការរាជធានី ខេត្ត

៣.សេចក្តីណែនាំនិយាម ស្តីពីការគ្រប់គ្រងមតិជំទាស់ និងសំណូមពររបស់មន្ត្រីតាមដានត្រួតពិនិត្យការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃមន្ទីរផែនការរាជធានី ខេត្ត។

សេចក្តីណែនាំនិយាមនេះ គឺជាគោលការណ៍រួមមួយដើម្បីធានាដល់ការអនុវត្តប្រកបដោយគុណភាព និងប្រសិទ្ធភាពដោយបានកំណត់ជំហាននីមួយៗ តួនាទី និងការទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពចុះតាមដានត្រួតពិនិត្យ និងការគ្រប់គ្រងមតិជំទាស់ និងសំណូមពរ ដើម្បីធានាថាទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យឆ្លើយតបទៅនឹងគោលនយោបាយជាតិគាំពារសង្គម និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ បញ្ចកោណទី១ "ការអភិវឌ្ឍមូលធនមនុស្ស" មុំទី៤ "ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធសុខាភិបាល" របស់រាជរដ្ឋាភិបាលនីតិកាលទី៧។

ក្រសួងផែនការសង្ឃឹមថា លោក លោកស្រី ដែលជាមន្ត្រីតាមដានត្រួតពិនិត្យ និងគ្រប់គ្រងមតិជំទាស់ និងសំណូមពរ និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តតាមសេចក្តីណែនាំនិយាមនេះ ដើម្បីសម្រេចឱ្យបានលទ្ធផលជាវិជ្ជមាននូវការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងនិភ័យ ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់របស់ប្រព័ន្ធគាំពារសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ប៊ិន ត្រឈៃ**

# ជំពូក១

# សេចក្តីណែនាំនិយាម ស្តីពីការចុះតាមដានត្រួតពិនិត្យ និងការបណ្តុះបណ្តាលបន្ថែម របស់មន្ត្រីនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

## ១.១. គោលបំណងនៃសេចក្តីណែនាំនិយាម

សេចក្តីណែនាំនិយាមនេះ មានគោលបំណងកំណត់ជំហាននីមួយៗ តួនាទី និងការទទួលខុសត្រូវនៃការអនុវត្តសកម្មភាពចុះតាមដានត្រួតពិនិត្យរបស់មន្ត្រីនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីពង្រឹងគណនេយ្យភាព ធានាគុណភាព សង្គតិភាពការងារ និងធ្វើឱ្យប្រាកដសម្រេចបាននូវគោលបំណងដែលបានរំពឹងទុក។

## ១.២.សកម្មភាពតាមដានត្រួតពិនិត្យ និងការបណ្តុះបណ្តាលបន្ថែម

ការតាមដានត្រួតពិនិត្យ និងការបណ្តុះបណ្តាលបន្ថែមនេះមានគោលបំណងដើម្បីៈ

- វាយតម្លៃពីសមត្ថភាពរបស់ក្រុមលេខាធិការដ្ឋាន (មន្ត្រីមន្ទីរផែនការរាជធានី ខេត្ត) និងក្រុមការងារឃុំ សង្កាត់ (ថ្នាក់ឃុំ សង្កាត់) ក្នុងការគ្រប់គ្រង ការអនុវត្តនីតិវិធី រួមទាំងការផ្តល់ចំណេះដឹងក្នុងការប្រើប្រាស់មុខងារនានានៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- កែលម្អដំណើរការអនុវត្តដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងនិរន្តរភាពនៃការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ តាមរយៈការពង្រឹងចំណេះដឹង ជំនាញបច្ចេកទេស និងការទទួលខុសត្រូវ
- ផ្តល់ឱកាសដល់អ្នកអនុវត្ត និងអ្នកគ្រប់គ្រងនៅថ្នាក់ក្រោមជាតិអាចបញ្ចេញមតិយោបល់អំពីវឌ្ឍនភាព ចំណុចខ្លាំង ចំណុចត្រូវកែលម្អ និងសំណូមពរ
- ដើម្បីឱ្យថ្នាក់ដឹកនាំបានទទួលព័ត៌មានទូលំទូលាយអំពីស្ថានភាពនៃការអនុវត្តសកម្មភាពនៅថ្នាក់មូលដ្ឋាន។

## ១.៣.សកម្មភាពមុនពេលចុះតាមដាន

ក. <u>ការរៀបចំសំណាកឃុំ សង្កាត់</u>

- រៀងរាល់ដើមត្រីមាសនីមួយៗត្រូវបង្កើត និងរៀបចំសំណាកចៃដន្យសម្រាប់ចុះតាមដានត្រួតពិនិត្យនៅថ្នាក់រាជធានី ខេត្ត និងឃុំ សង្កាត់
- រៀបចំប្រជុំជាមួយតំណាងក្រុមគាំទ្រ និងផ្តល់បច្ចេកទេសតាមរាជធានី ខេត្ត ដើម្បីកំណត់លើទីតាំងភូមិសាស្ត្រ (សំណាកឃុំ សង្កាត់ដោយចៃដន្យ ឬ/និងឃុំ សង្កាត់ ដែលមានភាពមិនប្រក្រតី) និងកាលបរិច្ឆេទសម្រាប់ចុះតាមដានត្រួតពិនិត្យ។

**ខ. ការរៀបចំផែនការសកម្មភាពចុះតាមដានត្រួតពិនិត្យ**

- ត្រូវរៀបចំសកម្មភាពចុះតាមដានត្រួតពិនិត្យ និងកំណត់ទីតាំងភូមិសាស្ត្រ ពេលវេលាឱ្យបានច្បាស់លាស់តាមទម្រង់បែបបទ៖ ***ផែនការសកម្មភាពសម្រាប់ចុះតាមដានត្រួតពិនិត្យសម្រាប់នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ***
- ត្រូវផ្ញើផែនការសកម្មភាពចុះតាមដានត្រួតពិនិត្យជូនមន្ទីរផែនការរាជធានី ខេត្តដើម្បី៖
  - ជូនដំណឹងដល់ថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ពីការចុះតាមដានត្រួតពិនិត្យរបស់ថ្នាក់ជាតិ យោងតាមផែនការសកម្មភាព ស្តីពីការចុះតាមដានត្រួតពិនិត្យ
  - ជូនដំណឹងដល់អ្នកសម្របសម្រួលបច្ចេកទេស មន្ត្រីទទួលបន្ទុកការងារតាមដានត្រួតពិនិត្យ និងមន្ត្រីទទួលបន្ទុកគ្រប់គ្រងទិន្នន័យរបស់មន្ទីរផែនការរាជធានី ខេត្ត ដើម្បីចូលរួមឆ្លុះបញ្ចាំងពីសកម្មភាពតាមដានត្រួតពិនិត្យរបស់ក្រុមការងារថ្នាក់ជាតិ
- រៀបចំឯកសារ និងសម្ភារៈសំខាន់ៗដូចជា (សៀវភៅនីតិវិធី សៀវភៅណែនាំស្តីពីការប្រើប្រាស់ថាប្លេត ថាប្លេត ដែលមានមុខងារតាមដានត្រួតពិនិត្យ និងសម្ភារៈផ្សព្វផ្សាយ)។ល។

## ១.៤. អំឡុងពេលចុះតាមដានត្រួតពិនិត្យ

មន្ត្រីតាមដានត្រួតពិនិត្យ ត្រូវចុះប្រមូលព័ត៌មាននៅថ្នាក់ឃុំ សង្កាត់ ជាមុនសិន បន្ទាប់មកត្រូវជួបប្រជុំជាមួយក្រុមលេខាធិការដ្ឋាន និងអ្នកសម្របសម្រួលបច្ចេកទេសនៃមន្ទីរផែនការរាជធានី ខេត្ត។

ក. សកម្មភាពសម្ភាសន៍ឃុំ សង្កាត់ និងបណ្តុះបណ្តាលបន្ថែម

- មុនចាប់ផ្តើម មន្ត្រីសម្ភាសន៍ត្រូវចុចសញ្ញាបង្ហាញ ស្ថិតិឃុំ សង្កាត់ ដើម្បីពិនិត្យទិន្នន័យដែលបានអនុវត្តក្នុងរយៈពេល៦ខែ និង១ឆ្នាំកន្លងមក (ចំនួនភូមិ ដើម្បីផ្ទៀងផ្ទាត់ចំនួនសមាសភាពក្រុមការងារឃុំ សង្កាត់ អត្រាភាពក្រីក្រ ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ និងការធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ) ដើម្បីបញ្ជាក់ពីស្ថានភាព និងសកម្មភាពការអនុវត្តរបស់ឃុំ សង្កាត់
- ប្រជុំជាមួយក្រុមការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រថ្នាក់ឃុំ សង្កាត់ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ផ្សេងទៀត ដើម្បីសម្ភាសន៍ និងស្រង់ព័ត៌មានដោយប្រើប្រាស់មុខងារតាមដានត្រួតពិនិត្យ
- ពិនិត្យមើលនូវឯកសារពាក់ព័ន្ធ និងការរក្សាទុករបាយការណ៍ ស្តីពីការប្រជុំអនុម័តចំណាត់ថ្នាក់គ្រួសារក្រីក្រ ដើម្បីជាភស្តុតាងអំពីការសម្រេចចិត្តផ្លូវការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ពង្រឹងសមត្ថភាព និងណែនាំបន្ថែមលើចំណុចដែលត្រូវកែលម្អ ដូចខាងក្រោម៖
  - នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ(ដំណើរការផ្តល់បណ្ណសមធម៌)
  - នីតិវិធីធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ (ដំណើរការដកគ្រួសារចេញពីបញ្ជីគ្រួសារក្រីក្រ និងការកែសម្រួលព័ត៌មានរបស់គ្រួសារ)

  - វិធីសាស្ត្រដោះស្រាយមតិជំទាស់ និងសំណូមពរ

  - ការចូលមើលស្ថិតិលើគេហទំព័រអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ https://app.idpoor.gov.kh
- ការសាកល្បងអនុវត្តមុខងារនៅលើកម្មវិធី IDPoor ដោយក្រុមការងារឃុំ សង្កាត់ និងណែនាំបន្ថែមលើចំណុចត្រូវកែលម្អអំពីៈ
  - មុខងារកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
  - មុខងារកែសម្រួលព័ត៌មានរបស់គ្រួសារ
  - មុខងារដកគ្រួសារចេញពីបញ្ជីគ្រួសារក្រីក្រ
  - មុខងារដោះស្រាយមតិជំទាស់ និងសំណូមពរ
- មន្ត្រីតាមដានត្រួតពិនិត្យ ត្រូវត្រួតពិនិត្យឡើងវិញនូវព័ត៌មានដែលបានសម្ភាសន៍ រួចធ្វើការវាយតម្លៃជារួមពីការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យរបស់ឃុំ សង្កាត់ដែលបានប្រមូលព័ត៌មានមុនពេលបញ្ជូនទិន្នន័យមកប្រព័ន្ធមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រនៃក្រសួងផែនការ។

## ខ. សកម្មភាពសម្ភាសន៍គ្រួសារ

- សម្ភាសន៍គ្រួសារតាមសំណាកដែលបានបង្កើតពីប្រព័ន្ធមូលដ្ឋានទិន្នន័យ ឬមុខងារតាមដានត្រួតពិនិត្យ ដោយចុចលើប៊ូតុង បង្កើតគ្រួសារ
- ករណីមានគ្រួសារអវត្តមានត្រូវចុចប៊ូតុង ដាក់អវត្តមាន នោះប្រព័ន្ធនឹងផ្លាស់ប្តូរគ្រួសារថ្មីដោយស្វ័យប្រវត្តិ។ (*បញ្ជាក់៖ ដើម្បីផ្លាស់ប្តូរគ្រួសារថ្មីបាន ឧបករណ៍ថាប្លេតត្រូវភ្ជាប់អ៊ីនធឺណេតនឹងមានគ្រួសារដែលបានកំណត់អត្តសញ្ញាណគ្រួសារក្នុងរយៈពេល ៦ខែចុងក្រោយ*)
- មន្ត្រីសម្ភាសន៍ត្រូវបញ្ជាក់ដល់គ្រួសារថា "ការសម្ភាសន៍នេះគឺក្នុងសកម្មភាពតាមដានត្រួតពិនិត្យដើម្បីវាយតម្លៃលើគុណភាពទិន្នន័យតែប៉ុណ្ណោះ"
- រាល់លទ្ធផលនៃការសម្ភាសន៍មិនត្រូវបង្ហាញទៅគ្រួសារនោះទេ
- មន្ត្រីសម្ភាសន៍ត្រូវផ្តល់ព័ត៌មានដល់គ្រួសារ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
- ករណីមន្ត្រីសម្ភាសន៍រកឃើញភាពមិនប្រក្រតីណាមួយត្រូវរាយការណ៍ ជូនអង្គប្រជុំ ដូចខាងក្រោម៖
  - ចំពោះគ្រួសារដែលមានការលំបាកផ្នែកជីវភាពតែមិនមានបណ្ណសមធម៌ ឬបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ ត្រូវបញ្ចូលក្នុងនីតិវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យដើម្បីសម្ភាសន៍

- ចំពោះគ្រួសារដែលមានជីវភាពធូរធារតែមានបណ្ណសមធម៌ ឬបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ ត្រូវបញ្ចូលក្នុងនីតិវិធីការធ្វើបច្ចុប្បកម្មទិន្នន័យ ដើម្បីដកគ្រួសារចេញពីបញ្ជីគ្រួសារក្រីក្រ។

**គ. សកម្មភាពប្រជុំជាមួយមន្ទីរផែនការរាជធានី ខេត្ត និងបណ្តុះបណ្តាលបន្ថែម**

- រៀបចំកិច្ចប្រជុំជាមួយក្រុមលេខាធិការដ្ឋាន អ្នកសម្របសម្រួលបច្ចេកទេស មន្ត្រីទទួលបន្ទុកការងារតាមដានត្រួតពិនិត្យ និងមន្ត្រីទទួលបន្ទុកគ្រប់គ្រងទិន្នន័យដើម្បី៖
    - ផ្តល់ព័ត៌មានពីលទ្ធផល ដំណោះស្រាយ និងបញ្ហាប្រឈម ដែលបានរកឃើញពីសកម្មភាពតាមដានត្រួតពិនិត្យនៅថ្នាក់ឃុំ សង្កាត់របស់ក្រុមការងារថ្នាក់ជាតិ
    - ស្រង់ព័ត៌មានដោយប្រើប្រាស់មុខងារតាមដានត្រួតពិនិត្យសម្រាប់ថ្នាក់រាជធានី ខេត្ត។
- ផ្តល់ការណែនាំដល់អ្នកសម្របសម្រួលបច្ចេកទេស មន្ត្រីទទួលបន្ទុកការងារតាមដានត្រួតពិនិត្យ និងមតិជំទាស់និងសំណូមពរ និងមន្ត្រីទទួលបន្ទុកគ្រប់គ្រងទិន្នន័យក្នុងការបំពេញតួនាទីភារកិច្ចរបស់ខ្លួន (ដូចជា ការប្រើប្រាស់ប្រព័ន្ធទិន្នន័យ ការប្រើប្រាស់មុខងារតាមដានត្រួតពិនិត្យ និងការគ្រប់គ្រងដោះស្រាយមតិជំទាស់ និងសំណូមពរ)។ល។

## ១.៥. សកម្មភាពក្រោយពីចុះតាមដានត្រួតពិនិត្យ

- ការិយាល័យតាមដានត្រួតពិនិត្យនៃនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ៖
    - ត្រូវឆែកមើលក្នុងប្រព័ន្ធគ្រប់គ្រងការតាមដានត្រួតពិនិត្យ ថាតើទិន្នន័យដែលបានពីការចុះតាមដានត្រួតពិនិត្យបានបញ្ជូនដល់ប្រព័ន្ធមូលដ្ឋានទិន្នន័យថ្នាក់ជាតិរួចរាល់ហើយ ឬនៅ?
    - ត្រូវទាញរបាយការណ៍សូចនាករ ដើម្បីបញ្ចូលទិន្នន័យទៅក្នុងរបាយការណ៍៖ "***ចុះតាមដានត្រួតពិនិត្យការអនុវត្តការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ***" ដូចខាងក្រោម៖
        - ចូលទៅមុខងារការតាមដានត្រួតពិនិត្យនៃប្រព័ន្ធគ្រប់គ្រងការតាមដានត្រួតពិនិត្យ បន្ទាប់មកចូលទៅផ្ទាំងទិន្នន័យ និងប្រើប្រាស់តម្រងជ្រើសរើស យុទ្ធនាការ ទីតាំងសំណាក ដែលបានចុះទៅតាមដានត្រួតពិនិត្យ
        - ទាញទិន្នន័យដែលទទួលបានពីការសម្ភាសន៍ឃុំ សង្កាត់ ដោយជ្រើសរើសប្រភេទបញ្ជីសំណួរឃុំ សង្កាត់ និងជ្រើសរើសប្រភេទ "ក្រសួងផែនការ"។ រួចទាញរបាយការណ៍៖ "លទ្ធផលនៃការតាមដានត្រួតពិនិត្យសូចនាករ"
        - ទាញរបាយការណ៍សុក្រឹតភាពទិន្នន័យ ដែលទទួលបានពីការសម្ភាសន៍គ្រួសារ ដោយជ្រើសរើសប្រភេទបញ្ជីសំណួរគ្រួសារមានបណ្ណ ឬគ្រួសារមិនមានបណ្ណ ហើយទាញរបាយការណ៍៖ "***កំហុសក្នុងការមិនដាក់បញ្ចូល***" (Exclusion Error) និងរបាយការណ៍៖ "***កំហុសក្នុងការដាក់បញ្ចូល***" (Inclusion Error)។

- រៀបចំរបាយការណ៍៖ "***ចុះតាមដានត្រួតពិនិត្យការអនុវត្តការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ***" ដើម្បីផ្តល់ជូនប្រធាននាយដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងថ្នាក់ដឹកនាំក្រសួងផែនការ។

# ជំពូក២

# សេចក្ដីណែនាំនិយាម ស្ដីពីការចុះតាមដានត្រួតពិនិត្យ និងការបណ្ដុះបណ្ដាលបន្ថែម ដល់ឃុំ សង្កាត់របស់មន្ទីរផែនការរាជធានី ខេត្ត

## ២.១. គោលបំណងនៃសេចក្ដីណែនាំនិយាម

សេចក្ដីណែនាំនិយាមនេះ ដើម្បីកំណត់ជំហាននីមួយៗ តួនាទី និងការទទួលខុសត្រូវនៃការអនុវត្ត សកម្មភាពចុះតាមដានត្រួតពិនិត្យរបស់ក្រុមលេខាធិការដ្ឋាន និងមន្ត្រីសម្របសម្រួលបច្ចេកទេសនៃមន្ទីរ ផែនការរាជធានី ខេត្ត ដើម្បីពង្រឹងគណនេយ្យភាព ធានាគុណភាព សង្គតិភាពការងារ និងធ្វើឱ្យប្រាកដសម្រេច បាននូវគោលបំណងដែលបានរំពឹងទុក។

## ២.២. សកម្មភាពតាមដានត្រួតពិនិត្យ និងការបណ្ដុះបណ្ដាលបន្ថែម

ការចុះតាមដានត្រួតពិនិត្យ និងការបណ្ដុះបណ្ដាលបន្ថែមមានគោលបំណងដើម្បី៖

- វាយតម្លៃពីសមត្ថភាពរបស់ក្រុមការងារឃុំ សង្កាត់ ក្នុងការអនុវត្តនីតិវិធី រួមទាំងចំណេះដឹងក្នុងការ ប្រើប្រាស់មុខងារទាំងអស់នៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- កែលម្អដំណើរការអនុវត្ត ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងនិរន្តភាពនៃការកំណត់អត្ត សញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ តាមរយៈការពង្រឹងសមត្ថភាព ចំណេះដឹង ជំនាញបច្ចេកទេស និងការទទួលខុសត្រូវ
- ផ្ដល់ឱកាសដល់អ្នកអនុវត្តអាចបញ្ចេញមតិយោបល់អំពីវឌ្ឍនភាព ចំណុចខ្លាំង ចំណុចត្រូវកែលម្អ និងសំណូមពរ
- ដើម្បីឱ្យថ្នាក់ដឹកនាំបាន ព័ត៌មានទូលំទូលាយអំពីស្ថានភាពនៃការអនុវត្តសកម្មភាពនៅថ្នាក់មូលដ្ឋាន។

## ២.៣.សកម្មភាពមុនពេលចុះតាមដានត្រួតពិនិត្យ

### ក. ការរៀបចំសំណាកឃុំ សង្កាត់

- រៀងរាល់ដើមត្រីមាសនីមួយៗ ការិយាល័យតាមដានត្រួតពិនិត្យរបស់នាយកដ្ឋានអត្តសញ្ញាណកម្ម គ្រួសារក្រីក្រនៃក្រសួងផែនការ នឹងផ្ដល់សំណាកចៃដន្យដល់មន្ទីរផែនការរាជធានី ខេត្ត
- រៀងរាល់ដើមត្រីមាសនីមួយៗ មន្ត្រីទទួលបន្ទុកការងារតាមដានត្រួតពិនិត្យប្រើប្រាស់គណនីផ្ទាល់ខ្លួន (Monitoring User) ដើម្បីចូលទៅផ្ទាំងទំព័រដើមនៃប្រព័ន្ធមូលដ្ឋានទិន្នន័យ
- ចូលទៅមុខងារការតាមដានត្រួតពិនិត្យនៃប្រព័ន្ធគ្រប់គ្រងការតាមដានត្រួតពិនិត្យ។ បន្ទាប់មកចូល ទៅផ្ទាំងឃុំ សង្កាត់
- ស្វែងរកប៊ូតុងចុច៣ក្បែរតម្រង ទាញទិន្នន័យ រួចជ្រើសរើសបញ្ជីឈ្មោះសំណាកឃុំ សង្កាត់ជាតារាង Excel រួចរក្សាទុក ដើម្បីរៀបចំបែងចែកសំណាកឃុំ សង្កាត់សម្រាប់ការចុះតាមដានត្រួតពិនិត្យ។

**បញ្ជាក់៖ រាល់សំណាកប្រចាំត្រីមាសនឹងត្រូវបិទបញ្ចប់នៅចុងត្រីមាសនីមួយៗ។ ចំពោះសំណាកឃុំ សង្កាត់ ដែលមិនបានចុះតាមដានត្រួតពិនិត្យក្នុងត្រីមាសចាស់ នោះប្រព័ន្ធគ្រប់គ្រងការតាមដានត្រួតពិនិត្យនឹងបញ្ជូនសំណាកនេះទៅត្រីមាសបន្ទាប់ណាមួយ។*

### ខ. ការរៀបចំសំណាកគ្រួសារ

- រាល់ការទាញសំណាកគ្រួសារក្នុងឃុំ សង្កាត់នីមួយៗ ត្រូវទាញកៀកថ្ងៃដែលត្រូវចុះ ហើយអាចធ្វើបាន២របៀប ដូចខាងក្រោម៖

<u>ការទាញគ្រួសារពីផ្ទាំងឃុំ សង្កាត់លើប្រព័ន្ធទិន្នន័យ (Web-App)</u>

  - ចូលទៅផ្ទាំងបញ្ជីឈ្មោះសំណាកឃុំ សង្កាត់ រួចជ្រើសរើសតម្រងយុទ្ធនាការតាមត្រីមាស ដែលត្រូវចុះតាមដានត្រួតពិនិត្យស្វែងរកប៊ូតុង បង្កើតគ្រួសារ
  - ចុចលើឃុំ សង្កាត់ ដែលបានបង្កើតគ្រួសារ ដើម្បីបង្ហាញបញ្ជីគ្រួសារដែលបានជ្រើសរើសសម្រាប់សម្ភាសន៍ក្នុងសកម្មភាពតាមដានត្រួតពិនិត្យ។

<u>ការទាញគ្រួសារពីមុខងារការតាមដានត្រួតពិនិត្យក្នុងកម្មវិធី IDPoor លើថាប្លេត</u>

  - ចូលទៅមុខងារតាមដានត្រួតពិនិត្យនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ រួចស្វែងរកឃុំ សង្កាត់ដែលត្រូវចុះតាមដានត្រួតពិនិត្យ បន្ទាប់មកស្វែងរកប៊ូតុងសញ្ញា ប៊ូកពណ៌ស្វាយ ដើម្បីបង្កើតគ្រួសារសម្រាប់សម្ភាសន៍
  - ចុចលើឃុំ សង្កាត់ដែលបានបង្កើតគ្រួសារ ដើម្បីបង្ហាញបញ្ជីគ្រួសារដែលបានជ្រើសរើសសម្រាប់សម្ភាសន៍ក្នុងសកម្មភាពតាមដានត្រួតពិនិត្យ។

### គ. ការរៀបចំផែនការសកម្មភាព

- មន្ត្រីទទួលបន្ទុកការងារតាមដានត្រួតពិនិត្យ ត្រូវរៀបចំបែងចែងសំណាកឃុំ សង្កាត់ ដែលបានទាញពីប្រព័ន្ធមូលដ្ឋានទិន្នន័យ
- ប្រជុំរៀបចំកាលបរិច្ឆេទចុះតាមដានត្រួតពិនិត្យតាមសំណាក និងជូនដំណឹងដល់ថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ត្រូវរៀបចំឯកសារ និងសម្ភារៈសំខាន់ៗ សម្រាប់សកម្មភាពចុះតាមដានត្រួតពិនិត្យ។

## ២.៤. កំឡុងពេលចុះតាមដានត្រួតពិនិត្យ

### ក. សកម្មភាពសម្ភាសន៍ឃុំ សង្កាត់ និងបណ្ដុះបណ្ដាលបន្ថែម

- ចូលទៅមុខងារតាមដានត្រួតពិនិត្យ ហើយស្វែងរកឃុំ សង្កាត់ ដែលត្រូវសម្ភាសន៍
- មុនចាប់ផ្ដើមមន្ត្រីសម្ភាសន៍ ត្រូវចុចសញ្ញាបង្ហាញ ស្ថិតិឃុំ សង្កាត់ ដើម្បីពិនិត្យទិន្នន័យដែលបានអនុវត្តក្នុងរយៈពេល៦ខែ និង១ឆ្នាំកន្លងមក (ចំនួនភូមិ អាត្រាភាពក្រីក្រ ទិន្នន័យការកំណត់អត្តសញ្ញាណ

គ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ និងការធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ) ដើម្បីបញ្ជាក់ពីស្ថានភាព និងសកម្មភាពការអនុវត្តរបស់ឃុំ សង្កាត់។

- ប្រជុំជាមួយក្រុមការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រថ្នាក់ឃុំ សង្កាត់ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ផ្សេងទៀត ដើម្បីបញ្ជាក់ពី៖
    - គោលបំណងនៃកិច្ចប្រជុំ
    - ស្វែងយល់ពីការអនុវត្តរបស់ក្រុមការងារឃុំ សង្កាត់
    - បណ្តុះបណ្តាល និងផ្តល់ការណែនាំបន្ថែមដល់ក្រុមការងារឃុំ សង្កាត់ លើចំណុចដែលខ្វះខាត។
- ស្រង់ព័ត៌មានដោយប្រើប្រាស់មុខងារតាមដានត្រួតពិនិត្យ
- ពិនិត្យមើលនូវឯកសារសំខាន់ៗ និងការរក្សាទុករបស់ឃុំ សង្កាត់ ជាពិសេសរបាយការណ៍ស្តីពីការអនុម័តចំណាត់ថ្នាក់គ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ដើម្បីជាភស្តុតាងអំពីការសម្រេចចិត្តផ្លូវការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- បណ្តុះបណ្តាល និងណែនាំបន្ថែមលើចំណុចដែលត្រូវកែលម្អ ដូចខាងក្រោម៖
    - ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
    - ការធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
    - ការដោះស្រាយមតិជំទាស់ និងសំណូមពរ
    - ការចូលមើលសិត្ថិលើគេហទំព័រអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
- បន្ទាប់ពីសម្ភាសន៍ក្រុមប្រឹក្សាឃុំ សង្កាត់រួច បន្តការអនុវត្តលើមុខងារ IDPoor App ជាមួយក្រុមការងារឃុំ សង្កាត់ និងណែនាំបន្ថែមលើចំណុចត្រូវកែលម្អ ដូចជា មុខងារកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ មុខងារកែសម្រួលព័ត៌មានរបស់គ្រួសារ មុខងារដកគ្រួសារចេញពីបញ្ជីគ្រួសារក្រីក្រ និងមុខងារដោះស្រាយមតិជំទាស និងសំណូមពរ
- មន្ត្រីតាមដានត្រួតពិនិត្យ ត្រូវត្រួតពិនិត្យឡើងវិញនូវព័ត៌មានដែលបានសម្ភាសន៍ រួចធ្វើការវាយតម្លៃជារួមពីការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យរបស់ឃុំ សង្កាត់ ដែលបានប្រមូលព័ត៌មានមុនពេលបញ្ជូនទិន្នន័យមកប្រព័ន្ធមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រនៃក្រសួងផែនការ។

## ខ. សកម្មភាពសម្ភាសន៍គ្រួសារ

- សម្ភាសន៍គ្រួសារតាមសំណាកដែលបានបង្កើតពីប្រព័ន្ធមូលដ្ឋានទិន្នន័យ ឬមុខងារតាមដានតាមត្រួតពិនិត្យ ដោយចុចលើប៊ូតុង ចាប់ផ្តើមសម្ភាសន៍
- ករណីមានគ្រួសារអវត្តមានត្រូវចុចប៊ូតុង ដាក់អវត្តមាន នោះប្រព័ន្ធនឹងផ្លាស់ប្តូរគ្រួសារថ្មីដោយស្វ័យប្រវត្តិ។ ***កំណត់សម្គាល់៖ ដើម្បីផ្លាស់ប្តូរគ្រួសារថ្មីបាន ឧបករណ៍ថាប្លេតត្រូវភ្ជាប់អ៊ីនធឺណែតនឹងមានគ្រួសារដែលបានកំណត់អត្តសញ្ញាណគ្រួសារក្នុងរយៈពេល ៦ខែចុងក្រោយ។***

- មន្ត្រីសម្ភាសន៍ត្រូវបញ្ជាក់ដល់គ្រួសារថា "ការសម្ភាសន៍នេះក្នុងសកម្មភាពតាមដានត្រួតពិនិត្យ ដើម្បីវាយតម្លៃលើគុណភាពទិន្នន័យតែប៉ុណ្ណោះ"
- រាល់លទ្ធផលនៃការសម្ភាសន៍មិនត្រូវបង្ហាញទៅគ្រួសារនោះទេ
- មន្ត្រីសម្ភាសន៍ត្រូវផ្តល់ព័ត៌មានដល់គ្រួសារដើម្បីលើកកម្ពស់ការយល់ដឹងអំពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
- ករណីមន្ត្រីសម្ភាសន៍រកឃើញភាពមិនប្រក្រតីណាមួយត្រូវរាយការណ៍ ជូនអង្គប្រជុំ ដូចខាងក្រោម៖
  - ចំពោះគ្រួសារដែលមានការលំបាកផ្នែកជីវភាពតែមិនមានបណ្ណសមធម៌ ឬបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យ ត្រូវបញ្ចូលក្នុងនីតិវិធីកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យដើម្បីសម្ភាសន៍
  - ចំពោះគ្រួសារដែលមានជីវភាពធូរធារតែមានបណ្ណសមធម៌ ឬបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យត្រូវបញ្ចូលក្នុងនីតិវិធីការធ្វើបច្ចុប្បន្នកម្មទិន្នន័យ ដើម្បីដកគ្រួសារចេញពីបញ្ជីគ្រួសារក្រីក្រ។

## ២.៥. លទ្ធផលក្រោយពេលចុះតាមដានត្រួតពិនិត្យ

- មន្ត្រីចុះតាមដានត្រួតពិនិត្យត្រូវរាយការណ៍ពីលទ្ធផលការចុះតាមដានត្រួតពិនិត្យដល់មន្ត្រីទទួលបន្ទុកការងារតាមដានត្រួតពិនិត្យនៃមន្ទីរផែនការរាជធានី ខេត្ត
- មន្ត្រីទទួលបន្ទុកការងារតាមដានត្រួតពិនិត្យត្រូវឆែកមើលក្នុងប្រព័ន្ធគ្រប់គ្រងការតាមដានត្រួតពិនិត្យថាតើទិន្នន័យដែលបានចុះតាមដានត្រួតពិនិត្យបានបញ្ជូនរួចរាល់ហើយ ឬនៅ?
- មន្ត្រីចុះតាមដានត្រួតពិនិត្យត្រូវរៀបចំឯកសាររដ្ឋបាលពាក់ព័ន្ធ ស្តីពីលទ្ធផលនៃការតាមដានត្រួតពិនិត្យ។

# ជំពូក៣
# សេចក្តីណែនាំនិយាម ស្តីពីការគ្រប់គ្រងមតិជំទាស់ និងសំណូមពររបស់មន្ត្រីតាមដានត្រួតពិនិត្យការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃមន្ទីរផែនការថ្នាក់រាជធានី ខេត្ត

## ៣.១. គោលបំណង

សេចក្តីណែនាំនេះមានគោលបំណងកំណត់អំពីដំណើរការ តួនាទីនៃការគ្រប់គ្រង និងដោះស្រាយមតិជំទាស់ និងសំណូមពររបស់មន្ទីរផែនការរាជធានី ខេត្ត និងឃុំ សង្កាត់ ដែលជាគោលការណ៍រួមមួយដើម្បីធានាដល់ការអនុវត្តប្រកបដោយគុណភាព និងនិរន្តរភាព។

## ៣.២. តួនាទី និងភារកិច្ច

មន្ត្រីទទួលបន្ទុកតាមដានត្រួតពិនិត្យ និងគ្រប់គ្រងមតិជំទាស់ និងសំណូមពររបស់មន្ទីរផែនការត្រូវចូលឆែកមើលផ្ទាំងព័ត៌មានបញ្ជីមតិជំទាស់ និងសំណូមពររៀងរាល់២ថ្ងៃម្តងជាប្រចាំ ដោយអនុវត្តតាមការណែនាំដូចខាងក្រោម៖

- ប្រើប្រាស់គណនីផ្ទាល់ខ្លួន (Monitoring User) ដើម្បីចូលទៅផ្ទាំងទំព័រដើមនៃប្រព័ន្ធមូលដ្ឋានទិន្នន័យ
- ចូលទៅបញ្ជីមតិជំទាស់ និងសំណូមពរ ដើម្បីពិនិត្យ៖ ប្រភេទមតិជំទាស់ និងសំណូមពរ ស្ថានភាព និងស្ថានភាពហួសពេលកំណត់ក្នុងការទទួលស្គាល់ ហួសការកំណត់ក្នុងការដោះស្រាយ កាលបរិច្ឆេទសំណើ និងភូមិសាស្ត្រ ឬក៏អាចទាញយករបាយការណ៍ទី១៨ និងទី១៩ ដែលពាក់ព័ន្ធនឹងទិន្នន័យមតិជំទាស់ និងសំណូមពរ
- ប្រើប្រាស់តម្រង (Filter) ដើម្បីពិនិត្យមើល៖
    - សំណើថ្មី
    - សំណើថ្មីដែលហួសកាលកំណត់ទទួលស្គាល់
    - សំណើបានទទួលស្គាល់ដែលហួសកាលកំណត់ដោះស្រាយ
- ប្រើប្រាស់តម្រង (Filter) ជ្រើសរើសភូមិសាស្ត្រដើម្បីកំណត់ទីតាំងជាក់លាក់

## ៣.៣. ដំណោះស្រាយ

- មន្ត្រីទទួលបន្ទុកតាមដានត្រួតពិនិត្យ និងគ្រប់គ្រងមតិជំទាស់ និងសំណូមពរនៃមន្ទីរផែនការរាជធានី ខេត្ត ត្រូវជូនដំណឹងទៅដល់មន្ត្រីសម្របសម្រួលបច្ចេកទេសក្រុង ស្រុក ខណ្ឌ រាល់មតិជំទាស់ និងសំណូមពរដែលឃុំ សង្កាត់យឺតយ៉ាវក្នុងការដោះស្រាយ
- មន្ត្រីសម្របសម្រួលបច្ចេកទេស ត្រូវទំនាក់ទំនងដោយផ្ទាល់ទៅឃុំ សង្កាត់ បន្ទាប់ពីទទួលបានព័ត៌មានពីមន្ត្រីទទួលបន្ទុកតាមដានត្រួតពិនិត្យ និងគ្រប់គ្រងមតិជំទាស់ និងសំណូមពររបស់មន្ទីរផែនការ ដើម្បីជំរុញការដោះស្រាយមតិជំទាស់ និងសំណូមពរ និងត្រូវផ្តល់ការណែនាំបច្ចេកទេសបន្ថែមតាមតម្រូវការរបស់ឃុំ សង្កាត់

- មន្ត្រីទទួលបន្ទុកតាមដានត្រួតពិនិត្យ និងគ្រប់គ្រងមតិជំទាស់ និងសំណូមពររបស់មន្ទីរផែនការត្រូវពិនិត្យលទ្ធផលសកម្មភាពនៃការដោះស្រាយមតិជំទាស់ និងសំណូមពររៀងរាល់២ថ្ងៃម្តងជាប្រចាំ
- ក្នុងករណីឃុំ សង្កាត់ មិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់មុខងារដោះស្រាយមតិជំទាស់ និងសំណូមពរ ឬមិនបានដោះស្រាយ មន្ត្រីសម្របសម្រួលបច្ចេកទេសក្រុង ស្រុក ខណ្ឌ ឬមន្ត្រីទទួលបន្ទុកតាមដានត្រួតពិនិត្យ និងគ្រប់គ្រងមតិជំទាស់ និងសំណូមពររបស់មន្ទីរផែនការត្រូវចុះទៅជួយណែនាំដោយផ្ទាល់។

## ៣.៤. របាយការណ៍លទ្ធផល

មន្ត្រីទទួលបន្ទុកតាមដានត្រួតពិនិត្យ និងគ្រប់គ្រងមតិជំទាស់ និងសំណូមពរត្រូវទាញរបាយការណ៍ពីប្រព័ន្ធមូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (របាយការណ៍ទី១៨៖ ***ស្ថានភាពមតិជំទាស់ និងសំណូមពរ*** និងរបាយការណ៍ទី១៩៖ ***សកម្មភាពមតិជំទាស់ និងសំណូមពរ***) ដើម្បីរាយការណ៍ពីលទ្ធផលការងារដែលបានដោះស្រាយជូនដល់ប្រធានការិយាល័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងប្រធានមន្ទីរផែនការរាជធានី ខេត្តជារៀងរាល់ខែ។